# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ សសរ

## សេចក្តីសំរេច
## ស្តីពីការចាត់តាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១៣ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៦១៧ អនក្រ.តត ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៤ សមាជិកបំរុង ឥស្សរជន និង អគ្គលេខាធិការ អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា
- យោងតាមការចាំបាច់

### សំរេច

**ប្រការ ១ :** ត្រូវបានចាត់តាំងលោកជំទាវ ម៉ែន នារីសោភ័គ នាយិការងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ឱ្យទទួលបន្ទុកការងារកាកបាទក្រហមកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុង ប្រធានកាកបាទក្រហមកម្ពុជា ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com